# រាជបណ្ឌិត្យសភាកម្ពុជា

# លទ្ធផលកិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ
# នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅខែធ្នូ ឆ្នាំ២០១៧

( ចងក្រងដោយៈ RAC Media; ប្រភពឯកសារៈ កជភខ )

## ១-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧

ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តដឹកនាំប្រជុំពិនិត្យពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការសុខាភិបាល កាលពីសម័យប្រជុំ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧ បានចំនួន ០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **៧៨-** តិរច្ឆានភាព/បេស្យាលីតេ<br>អ. bestiality<br>បារ. bestialité( f. ) | ការរួមភេទរវាងមនុស្សជាមួយនឹងសត្វ។ |
| **៧៩- ទឹកប្រមាត់**<br>អ.bile<br>បារ.bile( f. ) | វត្ថុរាវអាល់កាឡាំងពណ៌លឿងបៃតងមានរសជាតិល្វីងដែលបញ្ចេញដោយថ្លើមសម្រាប់បន្សាបអាស៊ីដក្នុង អាហារនៅដើមពោះវៀនតូច។ |
| **៨០- ប៊ីស្ទូរី**<br>អ.bistoury<br>បារ.bistouri ( m ) | ឧបករណ៍វេជ្ជសាស្ត្រដែលជាកាំបិតតូចៗមានច្រើនប្រភេទសម្រាប់ប្រើក្នុងការវះកាត់។ |
| **៨១- របួស**<br>អ.  injury<br>បារ. blessure ( f. ) | ភាពដាច់រហែកជាលិកានៃសរីរាង្គដែលបង្កដោយគ្រោះថ្នាក់ផ្សេងៗ។ |
| **៨២- បន្ទប់វះកាត់/សល្យសាល**<br>អ. operating room/<br>operating theaters<br>បារ. bloc opératoire ( m. ) | បន្ទប់ស្តេរីលស្អាតមានអនាម័យត្រឹមត្រូវនៅក្នុងមន្ទីរពេទ្យ ដែលបំពាក់ដោយបរិក្ខារសម្រាប់ការវះកាត់តូចធំនិង ការព្យាបាលផ្សេងៗ។ |

## ២-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧

ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តដឹកនាំប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជា ក្នុងសម័យប្រជុំ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ បានចំនួន០២ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- គោលជំហរ**<br>អ. attitude (position)<br>បារ. l'attitude (position) | សភាពនៃការយល់ព្រមឬការមិនយល់ព្រមខាងគំនិត ការពេញចិត្តឬការមិនពេញចិត្ត ដែលទាក់ទងនឹងវេទនារម្មណ៍និងអារម្មណ៍ ហើយដែល ផ្ទុយទៅនឹងជំនឿ។<br>ជំនឿទាក់ទងនឹងហេតុការណ៍និងការគិត ចំណែកឯគោលជំហរវិញទាក់ទងនឹងការវាយតម្លៃនឹងការឆ្លើយតបខាងវេទនារម្មណ៍។<br>មនុស្សដែលមានជំនឿដូចគ្នា អាចមានគោលជំហរខុសគ្នា ឬក៏មនុស្ស ដែលមានគោលជំហរដូចគ្នាអាចមានជំនឿខុសគ្នាចំពោះកម្មវត្ថុតែមួយ។ ដូច្នេះ ការខុសគ្នារវាងគោលជំហរនិងជំនឿ ដូចគ្នាទៅនឹងការខុសគ្នារវាង តម្លៃនិងហេតុការណ៍។ សីលវិជ្ជាអត្តនោម័តិ អះអាងថា គោលជំហរទាក់ ទងដោយផ្ទាល់នឹងហេតុផលជំរុញនិងឥរិយាបថ និងអះអាងថា ការវិនិច្ឆ័យ ខាងសីលវិជ្ជានិងខាងតម្លៃគឺជាបញ្ហានៃគោលជំហរជាជាងបញ្ហានៃការគិត។<br>(ពាក្យនេះប្រើនៅក្នុងសីលវិជ្ជានិងទស្សនវិជ្ជាស្ដីពីអំពើ)។ |
| **២- អាជ្ញា**<br>អ. authority<br>បារ. autorité | សិទ្ធិអំណាចដែលកាន់កាប់ដោយមនុស្សម្នាក់ ស្ថាប័នមួយ ឬរដ្ឋមួយដើម្បីចេញបញ្ជាឱ្យគោរព។ សិទ្ធិនេះបញ្ជាក់ពីកាតព្វកិច្ចមួយ ដែលអ្នកនៅក្រោមបង្គាប់នៃអាជ្ញានេះត្រូវតែគោរពនិងអនុវត្តតាម។<br>អាជ្ញា គឺជាប្រភេទមួយនៃអំណាច ប៉ុន្តែអំណាចទាំងអស់មិនមែនសុទ្ធ តែជាអាជ្ញាទេ។ ប្រភេទអំណាចមួយចំនួនគ្រាន់តែជាកម្លាំងបង្ខិតបង្ខំ ហើយវាមិនមានធម្មានុរូបភាពទេ។ អាជ្ញាអាចគ្រប់គ្រងតែតំបន់និងមនុស្សមួយចំនួនដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែមិនមែនគ្រប់គ្រងតំបន់និងមនុស្សផ្សេងទៀត ដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ខ្លួនទេ។ វិសាលភាពនិងព្រំដែននៃអាជ្ញារបស់រដ្ឋទាមទារឱ្យមានការពន្យល់។<br>ពាក្យនេះគេប្រើក្នុងបរិបទទស្សនវិជ្ជានយោបាយនិងទស្សនវិជ្ជាអំពីច្បាប់)។) |

## ៣-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៧

នៅថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានបន្តប្រជុំអនុម័តពាក្យគណៈកម្មការសុខាភិបាល បានចំនួន០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- **គំនាំងបេះដូង/ប្លុកបេះដូង**<br>អ. heart block<br>បារ. bloc cardiaque (m.) | វិបត្តិនៃ ចង្វាក់បេះដូងរហូតដល់គាំងដោយសារដាច់រលករំញោច(onde d'excitation)បញ្ជោសាច់ដុំបេះដូង បណ្ដាលមកពីការប្រើប្រាស់ឱសថខុសសារធាតុពុល ...។ |
| **២- ប៊ូយ៉ុង**<br>អ. bouillon/broth<br>បារ. bouillon (m.) | ទឹករម្ងាស់ជាតិសាច់ បន្លែ ... ប្រើក្នុងមីក្រុបវិទ្យាដើម្បីធ្វើជា ថ្នាលវប្បកម្ម។ |

| | |
|---|---|
| **៣- ថ្លាលវប្បកម្ម**<br>អ. culture medium<br>បារ. bouillon de culture (m.) | ប៊ូយ៉ុងសម្រាប់បណ្តុះនិងចិញ្ចឹមបាក់តេរី។ |
| **៤- ប៊ូលីមី**<br>អ. bulimia<br>បារ. boulimie(f.) | ជំងឺសរសៃប្រសាទម្យ៉ាងដែលបង្កឱ្យអ្នកជំងឺមានអាការៈឃ្លានខ្លាំង ស៊ីមិនដឹងឆ្អែត។ |
| **៥- ក្បាលបូស/គ្រាប់បូស**<br>អ. core of boil<br>បារ. bourbillon(m.) | ដុំសរសៃខ្ចពណ៌សនៅក្នុងបូសដែលកើតឡើងដោយសារការប្រមូលផ្តុំនៃជាលិកាស្បែកងាប់។ |

## ៤-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧

ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ដឹកនាំអង្គប្រជុំដោយឯកឧត្តមបណ្ឌិត ជួរ គារី បន្តប្រជុំអនុម័តបច្ចេកសព្ទ គណៈកម្មការទស្សនវិជ្ជា បានចំនួន៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- អាជ្ញានិយម**<br>អ. authoritarianism<br>បារ. l'autoritarisme (m.) | ទស្សនៈនយោបាយមួយដែលយល់ថាប្រជាពលរដ្ឋត្រូវតែគោរព អាជ្ញាធរជាដាច់ខាត ដោយមិនអនុញ្ញាតឱ្យសួរដេញដោលឡើយ។<br>ក្នុងការប្រតិបត្តិ នៅក្នុងប្រព័ន្ធនយោបាយផ្តាច់ការមួយ រដ្ឋាភិបាលមានអំណាចឥតព្រំដែននិងខ្វះការសង្កាប់បញ្ជាត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ។ អាជ្ញាធរអាចសម្រេចចិត្តដោយមិនចាំបាច់ពិគ្រោះយោបល់ឬចរចាជាមួយអ្នកដែលទទួលផលប៉ះពាល់ពីការអនុវត្តសេចក្តីសម្រេចចិត្តនោះឡើយ។ សង្គមបែបនេះត្រូវបានគ្រប់គ្រងដោយមនុស្សម្នាក់ឬមនុស្សមួយក្រុមជាជាងដោយច្បាប់។<br>(ពាក្យនេះគេប្រើក្នុងបរិបទទស្សនវិជ្ជានយោបាយ។) |
| **២- អសារនិយម**<br>អ. Nihilism<br>បារ. nihilisme (m.) | ១- ទស្សនៈដែលយល់ថា ជំនឿនិងតម្លៃជាប្រពៃណីគ្មានហេតុផលនិងថា អត្ថិភាពគ្មានន័យនិងគ្មានប្រយោជន៍។<br>២- ទស្សនៈដែលបដិសេធនូវមូលដ្ឋានសត្យានុម័តិនានានៃសច្ចភាព ជាពិសេស សច្ចភាពខាងសីលធម៌។<br>៣- ទស្សនៈដែលជឿថា គ្រប់អង្គការសាសនានិងនយោបាយអាក្រក់ណាស់ឬជាប្រព័ន្ធគំនិតមួយដែលថាគ្មានគោលការណ៍ឬជំនឿណាដែលមានន័យឬអាចជាការណ៍ពិតបានទេ។<br>ឧទាហរណ៍ ពួកអសារនិយមខាងសីលធម៌យល់ថា សីលធម៌គ្មានអត្ថិភាពពីធម្មជាតិទេ។ |
| **៣- អន្តរកម្មនិយម**<br>អ. Interactionism<br>បារ.interactionnisme (m.) | ទស្សនៈរបស់ពួកទ្វិកនិយមដែលអះអាងថា ថ្វីបើចិត្តនិងកាយជាសារ ធាតុពីរដាច់ដោយឡែកពីគ្នាក៏ដោយ ក៏វាជះឥទ្ធិពលលើគ្នាទៅវិញទៅមក តាមទំនាក់ទំនងហេតុផល។ ចិត្តនិងកាយជាធាតុពីរឯករាជ្យពីគ្នា ប៉ុន្តែនៅ ក្នុងជីវិតទាំងមូល កាយនឹងចិត្តមានអន្តរកម្មជាមួយគ្នា។<br>(ពាក្យនេះគេប្រើក្នុងបរិបទអស្តិរូបវិជ្ជានិងទស្សនវិជ្ជាអំពីចិត្ត។) |

## ៥-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧

ថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្តប្រជុំអនុម័តបច្ចេកសព្ទគណៈកម្មការសុខាភិបាលបានចំនួន១៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- មាត់**<br>អ. mouth<br>បារ.bouche(f.) | រង្វះរាងមូលទ្រវែងស្ថិតនៅខាងក្រោមច្រមុះចន្លោះថ្ពាល់នៃ មុខមនុស្ស រួមមាន បបូរមាត់ អញ្ចាញ ធ្មេញ អណ្ដាត និង ក្រពេញទឹកមាត់។ |
| **២- ផ្លុំមាត់និងមាត់**<br>អ. mouth-to-mouth (method)<br>បារ. bouche-à-bouche (méthode de) (f.) | វិធីសង្គ្រោះបន្ទាន់តាមផ្លូវដង្ហើមដល់ជនរងគ្រោះដែលទើបនឹងដាច់ដង្ហើម ដោយអ្នកសង្គ្រោះផ្លុំខ្យល់ពីមាត់របស់ខ្លួនបញ្ចូល ផ្ទាល់តាមមាត់ទៅក្នុងសួតជនរងគ្រោះ។ |
| **៣- ប្រង់កា**<br>អ. stretcher<br>បារ. brancard(m.)<br>civière(f.) | ឧបករណ៍វេជ្ជសាស្ត្រប្រើសម្រាប់សែងអ្នកជំងឺ ឬ អ្នករបួស ។ |
| **៤- ដើមដៃ**<br>អ. arm<br>បារ. bras (m.) | **កំណាត់អវយវៈលើរបស់មនុស្សស្ថិតនៅចន្លោះស្មានិងកែងដៃ។** |
| **៥- បង្ហើយ**<br>អ. bregma<br>បារ. bregma(m.)<br>fontanelle(f.) | ចំណុចប្រសព្វគ្នារវាងឆ្អឹងប៉ារីយេតាល់(pariétal)ទាំងពីរនិងឆ្អឹង ហ្វ្រុងតាល់(frontal)នៃឆ្អឹងលលាដ៍ក្បាលមនុស្ស។ |
| **៦- ក្លិនសា**<br>អ. bromhidrosis<br>បារ. bromhidrose/ bromidrose/osmidrose (f.) | **ញើសដែលផ្ទុំក្លិនមិនល្អនៅលើខ្លួនមនុស្សមួយចំនួន ជាពិសេសនៅត្រង់ក្លៀក។** |
| **៧- ទងសួត**<br>អ. bronchus<br>បារ. bronche(f.) | កំណាត់បំពង់ខ្យល់ទាំងពីរដែលបែកចេញពីបំពង់ខ្យល់ធំ (trachée-artère)ភ្ជាប់ទៅសួតទាំងសងខាង។ |
| **៨-អបាស៊ី**<br>អ. abasia<br>បារ. abasie(f.) | អាការៈដែលមិនអាចដើរបាន តែពុំមានការបាត់បង់ កម្លាំងសាច់ដុំនិងវេទយិតភាព(sensibilité)នៃសាច់ដុំទេ។ |
| **៩- ទុព្វលភាព**<br>អ. exhaustion<br>បារ. abattement(m.) | អាការៈថមថយកម្លាំងកាយឬកម្លាំងចិត្តយ៉ាងឆាប់រហ័សរបស់បុគ្គលណាមួយក្នុងរយៈពេលវែងឬខ្លី។ |
| **១០-ផ្ដាច់ដោះ**<br>អ. ablactation<br>បារ. ablactation(f.) | ការបញ្ឈប់បំបៅកូនដោយទឹកដោះម្ដាយ។ |

| | |
|---|---|
| ១១- អាប្លាស្យុង<br>អ. ablation/ resection<br>បារ. ablation(f.)<br>résection(f.) | ម. រេសិចស្យុង(résection)។ |
| **១២- អប្លេហ្វារី**<br>អ. ablephary<br>បារ. ablépharie(f.) | វិរូបភាពគ្មានត្របកភ្នែកពីកំណើត។ |
| **១៣- អឆន្ទៈ/ អប៊ូលី**<br>អ. aboulia/abulia<br>បារ. aboulie(f.) | វិបត្តិផ្លូវចិត្តសម្គាល់ដោយការបាត់បង់បំណងប្រាថ្នាក្នុងជីវិត។ |

## ៦-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជា បានចំនួន០២ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- ព្រលឹង**<br>អ. soul<br>បារ. âme | ផ្នែកអរូបធាតុដែលគេសន្មតថាមានវត្តមានតែនៅក្នុងភាវៈរស់ប៉ុណ្ណោះ។<br>ដោយសារតែហាក់ដូចជាគ្មានភាពខុសគ្នាខាងរូបធាតុរវាងភាវៈរស់នៅក្នុងខណៈនៃជីវិតដែលហៀបនឹងស្លាប់និងរាងកាយដែលទើបនឹងស្លាប់ថ្មីៗ ទើបទស្សនវិទូជាច្រើនតាំងពីសម័យប្លាតុង(Plato)បានអះអាងថា ព្រលឹង គឺជាសមាសភាគអរូបធាតុរបស់ភាវៈរស់។ដោយហេតុថាមានតែវត្ថុរូបធាតុប៉ុណ្ណោះដែលមានទីបញ្ចប់ ទើបប្លាតុងចាត់ទុកថាភាពអរូបធាតុរបស់ព្រលឹង ជាមូលដ្ឋាននៃអមតភាពរបស់ព្រលឹង។ ទាំងប្លាតុង ទាំងអារីស្តូត មិនបាន គិតថា មានតែមនុស្សទេដែលមានព្រលឹង៖ អារីស្តូត អះអាងថា ព្រលឹង ក៏មានចំពោះសត្វនិងរុក្ខជាតិដែរ ពីព្រោះសត្វនិងរុក្ខជាតិសុទ្ធតែបង្ហាញ មុខងារខ្លះជាភាវៈមានជីវិត។ ខុសពីប្លាតុង អារីស្តូតបដិសេធការចាក់ចេញ នៃព្រលឹងពីអម្បូរមួយទៅអម្បូរមួយទៀតឬពីរាងកាយមួយទៅរាងកាយមួយទៀតបន្ទាប់ពីការស្លាប់។ គាត់សង្ស័យចំពោះសមត្ថភាពចាកចេញពីរាងកាយ របស់ព្រលឹង ថាតើព្រលឹងអាចចាកចេញដោយរលូននៅមានជីវិតនិងបំពេញ មុខងារដោយគ្មានរាងកាយបានដែរឬទេ។<br>រ៉ឺណេ ដេកាត (**<u>René Déscartes</u>**) អះអាងថា មានតែមនុស្សទេដែលមានព្រលឹង និងអះអាងថាធម្មជាតិអរូបធាតុរបស់ព្រលឹងអាចបង្កើតសេរីភាព បានទោះបីជារាងកាយរបស់មនុស្សស្ថិតនៅឬមិនស្ថិតនៅក្រោមការកំណត់របស់ច្បាប់រូបធាតុក៏ដោយ។ |

| | |
|---|---|
| **២-ភាវៈមនុស្ស**<br>អ. human being<br>បារ. être humain | ចំពោះអារីស្តូត(Aristotle) «**ភាវៈមនុស្ស**» គឺជាសត្វប្រកបដោយវិចារណញ្ញាណ។ ចំពោះរ៉ឺណេដេកាត(**René Déscartes**) «**ភាវៈមនុស្ស**» មិនមែនជាសរីរាង្គតែមួយទេ ប៉ុន្តែវាជាបន្សំនៃធាតុខុសគ្នាពីរគឺចិត្តនិងកាយ។<br>ទោះបីជាមានភាពខុសគ្នាក្នុងការកំណត់បញ្ញត្តិភាវមនុស្សរវាងអារីស្តូតនិង រ៉ឺណេដេកាតក៏ដោយ ក៏អ្នកទាំងពីរបានចាត់ទុកថា វិចារណញ្ញាណ គឺជា លក្ខណៈសំខាន់ នៃភាវមនុស្ស។<br>ភាវមនុស្សត្រូវបានគេប្រើជាសទិសន័យជាមួយពាក្យ«មនុស្ស» ដែល គេយល់ថា ជាភាវៈមួយដែលមានសិទ្ធិមិនអាចដកហូតបាន ពោលគឺសិទ្ធិ រស់មានជីវិត និងសិទ្ធិមានសេរីភាព ព្រមទាំងជាភាវៈមួយខ្ពស់ជាងសត្វ ផ្សេងៗដែលមិនមែនជាមនុស្ស។<br>ទស្សនវិជ្ជាសីលធម៌សហសម័យមានទំនោរចង់ផ្តាច់ «មនុស្ស» ចេញពី «**ភាវៈមនុស្ស**» ដោយជឿថា «មនុស្ស» គឺជាភាវៈ ដែលមានស្វ័យញ◌ាណ ចំណែកឯ «**ភាវៈមនុស្ស**» គ្រាន់តែជាសមាជិកនៃពូជដើមរបស់មនុស្ស គឺអូម៉ូសាព្យាង(Homo sapiens) ប៉ុណ្ណោះ។<br>ពាក្យនេះគេប្រើនៅក្នុងអស្តិរូបវិជ្ជា សីលវិជ្ជា និងទស្សនវិជ្ជាអំពីចិត្ត)។) |

## ៧-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧

ថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានបន្តប្រជុំអនុម័តបច្ចេកសព្ទគណៈកម្មការសុខាភិបាលបានចំនួន០៦ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- អប្រាស៊ី<br>អ. abrachia<br>បារ. abrachie(f.) | វិរូបភាពគ្មានដៃពីកំណើត។ |
| ២- អប្រាស្យ៉ូសេហ្វាលី<br>អ.abrachiocephalia<br>បារ.abrachiocéphalie(f.) | វិរូបភាពចម្លែកដោយគ្មានដៃនិងគ្មានក្បាលពីកំណើត។ |
| ៣- អាប់រេអាក់ស្យុង<br>អ. abreactibn<br>បារ. abréaction(f.) | សភាពចិត្តរបស់អ្នកមានវិបត្តិផ្លូវចិត្តដែលកើតឡើងវិញនូវស្មារតីចង់ចំ◌ាចំពោះហេតុការណ៍ដែលបានភ្លេចបាត់ពីពេលកន្លងមក។ |
| ៤- បំណាក់ជាពីរ/អាប់រុបស្យុង<br>អ. abruption<br>បារ. abruption(f.) | ការបាក់ទទឹងឆ្អឹងជាពីរកំណាត់ដែលមានលក្ខណៈគគ្រាតត្រង់មុខបាក់។<br>[ពាក្យនេះប្រើក្នុងត្រូម៉ាតូវិទ្យា (traumatologie)]។ |
| ៥ - អវត្តមាន/អាប់សង់<br>អ. absence<br>បារ. absence (f.) | អាការៈបាត់ការចងចាំនិងអាចឈានដល់ការបាត់ស្មារតីមួយរយៈពេលខ្លី ដោយសារកង្វះឈាមទៅចិញ្ចឹមខួរក្បាល។<br>(ពាក្យនេះប្រើក្នុងជំនាញជំងឺផ្លូវចិត្ត)។ |
| ៦- ឱសថលាងរបួស<br>អាប់ស្ទែហ្សង់<br>អ.abstergent<br>បារ.abstergent(m.) | សារធាតុថ្នាំផ្សេងៗ ប្រើសម្រាប់លាងសម្អាតរបួស។ |